មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ

CCIM

cambodian center for independent media

OPC Cambodia

# អ្នកសារព័ត៌មានរាយការណ៍អំពីកូដកម្មការងារទទួលការគំរាមចាប់ខ្លួននៅភ្នំពេញ

ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២- មជ្ឈមណ្ឌលកម្ពុជា ដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) និងក្លឹបអ្នកសារព័ត៌មានបរទេសនៅកម្ពុជា (OPCC) ថ្កោលទោសការយាយី ការបំភិតបំភ័យនិងការគំរាមចាប់ខ្លួនអ្នកសារព័ត៌មានបរទេសនាពេលថ្មីៗនេះ ខណៈគាត់កំពុងរាយការណ៍អំពីសកម្មភាពកូដកម្មនៅក្នុងទីក្រុងភ្នំពេញ។ ឧបទ្ទវហេតុនេះ គឺជាការរំលោភលើសេរីភាពសារព័ត៌មានថ្មីបំផុតនៅកម្ពុជា។

កាលពីរសៀលថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២២ អ្នកសារព័ត៌មានរូបនោះកំពុងថតរូបនិងថតវីដេអូសកម្មភាពអាជ្ញាធរនិងកូដករកាស៊ីណូណាហ្គាវើលនៅទីសាធារណៈក្នុងរាជធានីភ្នំពេញ ពេលនោះមានបុរសម្នាក់ក្នុងសម្លៀកបំពាក់ធម្មតាដែលប្រាប់ថាខ្លួនជាមន្ត្រីអន្តោប្រវេសន៍ បានទៅរាំងអ្នកសារព័ត៌មានរូបនោះ និងទាមទាររកលិខិតឆ្លងដែននិងបណ្ណការងារ ប៉ុន្តែបានបដិសេធមិនបង្ហាញឯកសារបញ្ជាក់ពីតួនាទីរបស់ខ្លួនជាមន្ត្រីនោះទេ។

អ្នកសារព័ត៌មានរូបនោះ ដែលបម្រើការនៅបណ្តាញសារព័ត៌មាន VOD របស់មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) និងជាសមាជិកនៃក្លឹបអ្នកសារព័ត៌មានបរទេសនៅកម្ពុជាបានបង្ហាញបណ្ណសម្គាល់ខ្លួនដែលចេញដោយ CCIM និងស្នើបង្ហាញឯកសារចម្លងលិខិតឆ្លងដែនរបស់គាត់។

ទោះបីជាយ៉ាងណា មន្ត្រីរូបនោះបានទាមទាររកលិខិតឆ្លងដែនច្បាប់ដើមនិងបានគំរាមចាប់ខ្លួនអ្នកសារព័ត៌មានរូបនោះ ប្រសិនបើគាត់បន្តថតរូបនិងថតវីដេអូ និងមិនព្រមចាកចេញពីទីកន្លែងនោះ ដោយបង្ខំឱ្យអ្នកសារព័ត៌មានបញ្ឈប់ការធ្វើសេចក្តីរាយការណ៍និងចាកចេញពីទីនោះ។

ក្រុមមន្ត្រីដែលមានឯកសណ្ឋានបាននិយាយទៅកាន់បុរសដែលក្នុងសម្លៀកបំពាក់ធម្មតារូបនោះជាច្រើនលើក ខណៈពេលបុរសរូបនេះកំពុងសួរនាំអ្នកសារព័ត៌មាន។ បុរសរូបនោះក៏បានប្រាប់អ្នកសារព័ត៌មានផងដែរថា ខ្លួនហាមឃាត់មិនឱ្យថតដោយសារតែគាត់គឺជាអ្នកសារព័ត៌មាន។

ខណៈអាជ្ញាធរមានសិទ្ធិពង្រឹងការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ អ្នកសារព័ត៌មានក៏មានសិទ្ធិធ្វើសេចក្តីរាយការណ៍ព័ត៌មានផងដែរ។ ច្បាប់ស្តីពីរបបសារព័ត៌មានឆ្នាំ១៩៩៥ដែលនៅជាធរមាន ហាមឃាត់ការចាប់ពិរុទ្ធមុនការបោះពុម្ពផ្សាយ ដូចអ្វីដែលត្រូវបានបង្ហាញ អំឡុងពេលមានឧបទ្ទវហេតុកាលពីថ្ងៃទី៥នេះស្រាប់។

ប្រសិនបើសេរីភាពសារព័ត៌មានពិតជាមានមែននៅកម្ពុជា ដូច្នេះត្រូវតែអនុញ្ញាតឱ្យអ្នកសារព័ត៌មានទាំងអស់ធ្វើការងារដោយគ្មានការរារាំងដែលមិនត្រឹមត្រូវពីសំណាក់អាជ្ញាធរ។ ចំណុចនេះគឺរួមទាំងការធ្វើបទសម្ភាសជាមួយនឹងប្រភពដោយសេរី ការឃ្លាំងមើល ការថតរូបនិងការថតវីដេអូអំពីពលរដ្ឋ ព្រឹត្តិការណ៍និងសកម្មភាពនានានៅតាមទីសាធារណៈ។

នៅពេលអាជ្ញាធរប្រើប្រាស់អំណាចរបស់ខ្លួនតាមអំពើចិត្តនិងបំពានលើសេរីភាពសារព័ត៌មាន សង្គមនឹងប្រឈមកង្វះដំណឹងនិងព័ត៌មានដែលរកបានដោយសេរី។ យើងអំពាវនាវឱ្យបញ្ចប់ការរំលោភអំណាចតាមអំពើចិត្តទាំងឡាយ ព្រមទាំងការយាយីនិងការគំរាមកំហែងលើសហការីរបស់យើង។ យើងអំពាវនាវឱ្យមានការស៊ើបអង្កេតឯករាជ្យលើករណីរំលោភបំពានបែបនេះ។

CCIM និង OPCC នៅជាមួយនឹងអ្នកសារព័ត៌មានអាជីពទាំងអស់ដែលកំពុងប្រឈមនឹងការយាយីនិងការបំភិតបំភ័យ។ យើងគាំទ្រសេរីភាពសារព័ត៌មានដែលក្នុងនោះអ្នកសារព័ត៌មានអាចធ្វើការងារដោយគ្មានការភ័យខ្លាច៕

---

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក អ៊ិត សូធឿត ប្រធាននាយកដ្ឋានប្រព័ន្ធផ្សព្វផ្សាយនៃមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យតាមរយៈអ៊ីមែល៖ isothoeuth@vodhotnews.com ឬ 012 819 545 ឬទាក់ទងមកកាន់ក្លឹប OPCC តាមរយៈអ៊ីមែល៖ opcccambodia@gmail.com